**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១០ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការកំណត់តួនាទី និងភារកិច្ចប្រធាននិងអនុប្រធាន អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៦៥ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីវិសោធនកម្មមាត្រា៤ មាត្រា១០ និងមាត្រា១៣នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន
- បានឃើញអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន
- បានឃើញអនុក្រឹត្យលេខ១០០ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៥ ស្តីពីវិសោធនកម្មជំពូកទី៤ ជំពូកទី៥ ជំពូកទី៦ ជំពូកទី៧ ជំពូកទី៨ ជំពូកទី១៣ និងជំពូកទី១៥នៃអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន

- បានឃើញអនុក្រឹត្យលេខ៩២ អនក្រ.បក ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០០៧ ស្តីពីការកែសម្រួល មាត្រា៧ថ្មី ជំពូកទី៥ថ្មីនៃអនុក្រឹត្យលេខ១០០ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៥ និងការប្របាច់បញ្ចូល ជំពូកទី១០ និងជំពូកទី១១នៃអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន
- យោងតាមសំណូមពរចាំបាច់នៃការងារ

## សម្រេច

**ប្រការ១.-**

ត្រូវបានកំណត់តួនាទី និងភារកិច្ចប្រធាននិងអនុប្រធានអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ដែលតទៅនេះហៅថា អាជ្ញាធរមីន ដូចខាងក្រោម៖

១- ប្រធាន ទទួលបន្ទុកការងាររួមរបស់អាជ្ញាធរមីន។

២- អនុប្រធានទី១ ទទួលបន្ទុក ៖

- ដឹកនាំការងារទូទៅរបស់អាជ្ញាធរមីន ក្នុងនាមនិងជំនួសប្រធានអាជ្ញាធរមីន
- ដឹកនាំកិច្ចសហប្រតិបត្តិការទូទៅជាមួយដៃគូអភិវឌ្ឍ បណ្តាប្រទេស អង្គការជាតិ និងអន្តរជាតិនានា ព្រមទាំងក្រសួង ស្ថាប័ន អាជ្ញាធរដែនដី លើសកម្មភាពមីន
- រៀបចំ លើកសំណើតែងតាំង ផ្លាស់ប្តូរថ្នាក់ដឹកនាំ និងមន្ត្រីរបស់អាជ្ញាធរមីន ជូនប្រធានពិនិត្យសម្រេច
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធានអាជ្ញាធរមីន។

៣- អនុប្រធានទី២ ទទួលបន្ទុក ៖

- ជួយតាមដានការងារគណៈកម្មាធិការសកម្មភាពមីនរាជធានី ខេត្ត និងក្រុមការងារផែនការសកម្មភាពមីន
- ជួយតាមដានការងាររបស់ប្រតិបត្តិករសកម្មភាពមីន
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធានអាជ្ញាធរមីន។

៤- អនុប្រធាន ទទួលបន្ទុក ៖

- ជួយតាមដានការងារទំនុកបម្រុងជនរងគ្រោះដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម
- ជួយតាមដានការងាររៀបចំរបាយការណ៍សកម្មភាពមីន ជូនរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធានអាជ្ញាធរមីន។

**ប្រការ២.-**

សេចក្តីសម្រេចលេខ១៤៩ សសរ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៤ ស្តីពីការកំណត់តួនាទី និងភារកិច្ចប្រធាននិងអនុប្រធានអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១០កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ